ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភា
# ប្រចាំខែសីហា ឆ្នាំ២០១៧

នៅក្នុងខែសីហា ឆ្នាំ២០១៧នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចរបស់ខ្លួនដូចតទៅ:

## ១.សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា

### ១.១ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា បាន៖

-ទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទីចំនួន០១លើក

-អនុញ្ញាតឲ្យឯកឧត្តម **ជិន ថាញ់មិន** សមាជិកគណៈកម្មាធិការមជ្ឈឹមបក្សកុម្មុយនីស្ត វៀតណាម និងជាប្រធានគណៈកម្មាធិការមជ្ឈឹមបក្សរណសិរ្សមាតុភូមិវៀតណាម នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ចូលជួប និងសវនាការ

-ទទួលសារតាំងពីឯកឧត្តមបណ្ឌិត Adel Mohamed Ali BA Hamid ឯកអគ្គរដ្ឋទូតតែងតាំងថ្មីនៃសាធារណរដ្ឋយេមែន ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា

-អនុញ្ញាតឲ្យក្រុមនិស្សិតកម្ពុជាចំនួន១៦រូប ដែលទទួលអាហារូបករណ៍ Cheveing ពីរាជរដ្ឋាភិបាលអង់គ្លេស សម្រាប់ឆ្នាំ២០១៧-២០១៨ ចូលជួបសម្តែងការគួរសមក្នុងគោលបំណងដើម្បីទទួលនូវបទពិសោធន៍ និងអនុសាសន៍ណែនាំល្អៗពីសម្តេច

-អញ្ជើញជួបសំណេះសំណាលជាមួយថ្នាក់ដឹកនាំសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងការអភិវឌ្ឍខេត្តកំពង់ស្ពឺ

-អញ្ជើញជួបសំណេះសំណាល និងសាកសួរសុខទុក្ខជាមួយប្រជាពលរដ្ឋដែលជាអាជីវករលក់ដូរគ្រឿងសង្ហារឹម និងសម្ភារៈការិយាល័យ នៅសង្កាត់បឹងកេងកង៣ ខណ្ឌចំការមន រាជធានីភ្នំពេញ

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើព្រះរាជក្រមចំនួន០១ ព្រះរាជក្រឹត្យចំនួន៩០ ទទួលព្រះរាជសារព្រះរាជទានសិទ្ធិចំនួន៩៣ ទទួលសំណើពីរាជរដ្ឋាភិបាលចំនួន៤៤ ពីរដ្ឋសភាចំនួន០៣ ពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចំនួន០១ ពី

ស្តីទីព្រឹទ្ធសភាចំនួន០២ ពីក្រុមប្រឹក្សាធម្មនុញ្ញចំនួន០១ ពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមចំនួន០១ និងជ្រាបជាព័ត៌មានចំនួន៦៦ច្បាប់ ។

**១.២.ឯកឧត្តម នៃ ប៉េណា អនុប្រធានទី១ព្រឹទ្ធសភា បាន** :

-ទទួលភារកិច្ចជាប្រធានស្តីទីព្រឹទ្ធសភាចំនួន០១លើក

-អញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន០២លើក និងប្រជុំវិសាមញ្ញព្រឹទ្ធសភាចំនួន០១លើក

-អញ្ជើញទៅបំពេញទស្សនកិច្ចជាផ្លូវការ នៅសាធារណរដ្ឋសង្គមនិយមវៀតណាម

-អញ្ជើញចូលជួបសម្តែងការគួរសម និងរាយការណ៍ពីសកម្មភាពការងារមួយចំនួនជូនសម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រមុខរដ្ឋស្តីទីនៃព្រះរាជាណាចក្រកម្ពុជា

-អនុញ្ញាតឲ្យឯកឧត្តមបណ្ឌិតទេសរដ្ឋមន្ត្រី **ប៉ែន ស៊ីម៉ន** ទីប្រឹក្សាផ្ទាល់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម **ខួយ ឃុនហ៊ួរ** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ចូលជួបពិភាក្សាការងារ

-អញ្ជើញចុះជួបសំណេះសំណាលជាមួយអាជ្ញាធរ និងប្រជាពលរដ្ឋ នៅខេត្តកំពត

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន០៧ច្បាប់ និងជ្រាបជាព័ត៌មានចំនួន២៩ច្បាប់ ។

**១.៣.ឯកឧត្តម ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា បាន** :

-ទទួលភារកិច្ចជាប្រធានស្តីទីព្រឹទ្ធសភាចំនួន០១លើក

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន០១លើក និងប្រជុំវិសាមញ្ញព្រឹទ្ធសភាចំនួន០១លើក

-អញ្ជើញចូលរួមជាអធិបតីក្នុងសន្និសីទលើកទី១១ ស្តីពី ការពង្រឹងមិត្តភាពរវាងប្រជាជន និងប្រជាជនអាស៊ាន-ចិន ដើម្បីសន្តិភាព និងកិច្ចសហប្រតិបត្តិការជាមួយតំណាងសមាគមមិត្តភាពអាស៊ាន-ចិន ពីបណ្តាប្រទេសអាស៊ាន និងចិន នៅសណ្ឋាគារសុខាវីសត ខេត្តសៀមរាប

-អនុញ្ញាតឲ្យលោកជំទាវ Gabriela Cuevas Barron សមាជិកព្រឹទ្ធសភា និងជាប្រធានគណៈកម្មាធិការទំនាក់ទំនងការបរទេសនៃសហរដ្ឋម៉ិចស៊ិកូ ចូលជួបសម្តែងការគួរសម និងជួបពិភាក្សាការងារ នៅវិមានព្រឹទ្ធសភា

-អញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តមកពីប្រទេសបារាំង ទៅពិនិត្យ និងព្យាបាលជំងឺដោយឥតគិតថ្លៃជូនប្រជាពលរដ្ឋនៅស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៩១ច្បាប់ និង ជ្រាបជាព័ត៌មានចំនួន៦៦ច្បាប់ ។

**២.សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០២លើក:**

១.ពិនិត្យ និងសម្រេចលើសេចក្តីព្រាងសេចក្តីសម្រេចស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់គណៈកម្មការក្រមសីលធម៌ព្រឹទ្ធសភា

២.ពិនិត្យ និងសម្រេចលើសេចក្តីព្រាងសេចក្តីសម្រេចស្តីពី គោលការណ៍ក្រមសីលធម៌សភារបស់សមាជិកព្រឹទ្ធសភា

៣.ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការទី៦ព្រឹទ្ធសភា សុំដាក់សេចក្តីស្នើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

៤.អំពីនីតិវិធីបោះឆ្នោតជ្រើសរើសបំពេញសមាជិកគណៈកម្មការទី១០ព្រឹទ្ធសភា

៥.ពិនិត្យលើសំណើរបស់សមាជិកព្រឹទ្ធសភា ស្នើសុំកោះប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ

៦.កំណត់កាលបរិច្ឆេទ និងរបៀបវារៈ ប្រជុំវិសាមញ្ញព្រឹទ្ធសភា នីតិកាលទី៣ ។

**៣.ប្រជុំវិសាមញ្ញចំនួន០១លើក**

១.ពិនិត្យ និងអនុម័តលើសេចក្តីស្នើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

២.ការបោះឆ្នោតជ្រើសរើសបំពេញសមាជិកគណៈកម្មការទី១០ ព្រឹទ្ធសភា ។

**៤.គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា** :

ក្នុងខែសីហានេះ សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្ម តាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម:

**៤.១.មុខងារនីតិកម្ម**

-គណៈកម្មការជំនាញបានប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការព្រឹទ្ធសភាជាមួយតំណាងក្រុមព្រឹទ្ធសភាហត្ថលេខី ដើម្បីពិនិត្យពិភាក្សាលើសេចក្តីស្នើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ចំនួន០១ច្បាប់ ។

**៤.២.មុខងារតាមដានការអនុវត្តច្បាប់**

-អញ្ជើញចុះបំពេញបេសកកម្មសិក្សាឈ្វេងយល់អំពីការអនុវត្តច្បាប់អន្តោប្រវេសន៍ និងការផ្សព្វផ្សាយព័ត៌មាន នៅខេត្តកោះកុង ព្រះសីហនុ កំពត និងខេត្តតាកែវ

-អញ្ជើញចុះបំពេញបេសកកម្ម ដើម្បីសិក្សាឈ្វេងយល់អំពីការអនុវត្តច្បាប់ពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ ដោយផ្តោតលើបញ្ហាការធ្វើចំណាកស្រុក និងការទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ នៅខេត្តត្បូងឃ្មុំ ព្រៃវែង និងខេត្តស្វាយរៀង

-អញ្ជើញចុះតាមដានលទ្ធផលការងារ និងវឌ្ឍនភាពក្រោយពីការរៀបចំវេទិកាកន្លងមក និងឈ្វេងយល់ពីការប្រឈម និងសំណូមពររបស់ក្រុមប្រឹក្សាក្រុង ស្រុក អភិបាលក្រុង ស្រុក និងក្រុមប្រឹក្សាឃុំ សង្កាត់ នៅខេត្តក្រចេះ និងខេត្តស្ទឹងត្រែង ។

## ៤.៣.មុខងារតំណាង

-បានទទួលពាក្យបណ្តឹងចំនួន០៥ករណី ធ្វើលិខិតអន្តរាគមន៍ទៅស្ថាប័នមានសមត្ថកិច្ចដោះស្រាយបានចំនួន០៥ករណី ព្រមទាំងធ្វើកំណត់បង្ហាញពាក្យបណ្តឹងបានចំនួន០២ករណី ឆ្លើយតបទៅម្ចាស់បណ្តឹងបានចំនួន០៥ករណី និងទទួលពាក្យបណ្តឹងជូនជ្រាបចំនួន០៣ករណី

-ក្រុមសមាជិកាព្រឹទ្ធសភា បើកកិច្ចប្រជុំដើម្បីពិភាក្សាពីការត្រៀមរៀបចំវេទិការបស់ក្រុមសមាជិកាព្រឹទ្ធសភានៅភូមិភាគទី៨ ខេត្តរតនគិរី

-ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ បើកកិច្ចប្រជុំដើម្បីពិនិត្យ ពិភាក្សាស្តីពីការត្រៀមរៀបចំវេទិកាថ្នាក់ខណ្ឌ និងការរៀបចំសម្ពោធស្រះទឹកត្រពាំងធំមួយកន្ធែងនៅសង្កាត់ភ្លើងឆេះរទេះ ខណ្ឌពោធិ៍សែនជ័យ ជូនប្រជាពលរដ្ឋប្រើប្រាស់ជាផ្លូវការ និងបញ្ហាផ្សេងៗដែលត្រូវអនុវត្តបន្ត

-ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ បើកកិច្ចប្រជុំដើម្បីពិនិត្យពិភាក្សាអំពីគម្រោងរៀបចំវេទិកាថ្នាក់ខេត្តស្តីពី កិច្ចពិគ្រោះយោបល់សាធារណៈ និងពង្រឹងសមត្ថភាពការងារកសាងផែនការអភិវឌ្ឍមូលដ្ឋាន នៅខេត្តប៉ៃលិន

-អញ្ជើញចូលរួមប្រជុំការងារក្រុមមិត្តភាពទ្វេភាគីព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ជាមួយសភាសាធារណរដ្ឋសង្គមនិយមវៀតណាម ដើម្បីបូកសរុបរបាយការណ៍សកម្មភាព និងរបាយការណ៍ថវិកាប្រចាំឆមាសទី១ ឆ្នាំ២០១៧ និងទិសដៅអនុវត្តការងារបន្ត

-អញ្ជើញចូលរួមពិធីសម្ពោធដាក់ឲ្យប្រើប្រាស់អណ្តូងទឹកស្អាតចំនួន០២ ដែលឧបត្ថម្ភដោយអង្គការវិទ្យាស្ថានសន្ទនាមេគង្គ (MDI) ជូនប្រជាពលរដ្ឋនៅភូមិត្រពាំងខ្លា និងភូមិប្រផាត់ ឃុំរកាពប្រាំ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ

-អញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំក្រុមការងារថ្នាក់ដឹកនាំ សមាជិក សមាជិកាសមាគមអ្នកចិញ្ចឹមសត្វកម្ពុជា ដើម្បីពិនិត្យរបាយការណ៍បច្ចុប្បន្នភាពរបស់សមាគមអ្នកចិញ្ចឹមសត្វកម្ពុជា និងការលើកឡើងបង្ហាញអំពីផែនការជាយុទ្ធសាស្ត្ររបស់សមាគមសម្រាប់អនុវត្តបន្ត

-អញ្ជើញចូលរួមប្រជុំដើម្បីត្រៀមរៀបចំកិច្ចប្រជុំ APFតំបន់អាស៊ីប៉ា-ស៊ីហ្វិចលើកទី៨

-អញ្ជើញជួបពិភាក្សាការងារជាមួយតំណាងអង្គការសុខភាពពិភពលោក(WHO) អំពីគម្រោងរៀបចំបេសកកម្មទៅប្រទេសជប៉ុន ដើម្បីចូលរួមវេទិកាសភាតំបន់អាស៊ីប៉ាស៊ីហ្វិច នៅប្រទេសជប៉ុន

-អញ្ជើញចូលរួមប្រជុំដើម្បីពិនិត្យ និងពិភាក្សាលើគម្រោងថវិកាព្រឹទ្ធសភាឆ្នាំ២០១៨

-អនុញ្ញាតឲ្យអង្គការអភិរក្សសត្វព្រៃអាស៊ីរបស់ USAID តាមរយៈអគ្គលេខាធិការដ្ឋានអន្តរសភាអាស៊ាន (AIPA) ចូលជួបពិភាក្សាការងារជាមួយគណៈកម្មការ និងសមាជិកព្រឹទ្ធសភាកម្ពុជាស្តីពី ការស្វែងរកការគាំទ្របន្ថែមទៀតពីសមាជិក (AIPA) ក្នុងកិច្ចខិតខំប្រឹងប្រែងទប់ស្កាត់បទល្មើសសត្វព្រៃនៅតំបន់អាស៊ាន ព្រមទាំងពិភាក្សាលើសេចក្តីព្រាងក្រមបរិស្ថាន និងធនធានធម្មជាតិ

-អញ្ជើញជួបពិភាក្សាការងារជាមួយលោកស្រី Somsook Boonyabancha ប្រធានអង្គការសម្ព័ន្ធភាពអាស៊ីដើម្បីសិទ្ធិលំនៅដ្ឋានស្តីពី ការអនុវត្តគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល និងអង្គការ Habitat for humanity អំពីគម្រោងរៀបចំវេទិកាលំនៅដ្ឋានតំបន់អាស៊ី-ប៉ាស៊ីហ្វិច

សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះតាមបណ្តាខេត្ត ក្រុង រាជធានីទូទាំងប្រទេសចំនួន២០០លើក ដើម្បីចុះជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ កងទ័ព សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យព្យាបាលជំងឺជូនប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ឈ្វេងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន៩៨លើក ។

**៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ** :

-ឯកឧត្តម **ឈិត គឹមយាត** អញ្ជើញចូលរួមជាភ្ញៀវកិត្តិយស និងជាវាគ្មិននៃវេទិកាអភិវឌ្ឍប្រកបរបៀងសេដ្ឋកិច្ចអន្តរជាតិលើកទី២ រវាងចិន និងឧបទ្វីបឥណ្ឌូចិន ប្រចាំឆ្នាំ២០១៧ នៅខេត្តchengdu នៃសាធារណរដ្ឋប្រជាមានិតចិន

- លោកជំទាវ **មាន សំអាន** លោកជំទាវ **ជិន សុជីម** និងឯកឧត្តម **អន ស៊ុំ** អញ្ជើញទស្សនកិច្ចផ្លូវការ នៅសាធារណរដ្ឋសង្គមនិយមវៀតណាម

-ឯកឧត្តម **វ៉ាន់ វុធ** និងលោកជំទាវ **កែវ ម៉ាលី** អញ្ជើញចូលរួមសន្និសីទលើកទី៦ នៃគណៈកម្មការកិច្ចការបរទេសនៃសភាប្រទេសទាំងបី កម្ពុជា-ឡាវ-វៀតណាម (CLV) នៅទីក្រុងវៀងច័ន្ទ សាធារណរដ្ឋប្រជាមានិតឡាវ

-ឯកឧត្តម **អាំ សំអាត** អញ្ជើញចូលរួមកិច្ចប្រជុំលើកទី៣ នៃវេទិកាសមាជិកសភាអាស៊ី-ប៉ាស៊ីហ្វិចស្តីពី សុខភាពសកល នៅទីក្រុងតូក្យូ ប្រទេសជប៉ុន

-ឯកឧត្តម **ប៊ូ ថង** អញ្ជើញជួបសំណេះសំណាល និងផ្លាស់ប្តូរព័ត៌មានថ្មីៗជាមួយ ឯកឧត្តមឯកអគ្គរដ្ឋទូតឡាវប្រចាំនៅព្រះរាជាណាចក្រកម្ពុជា

-អញ្ជើញជួបពិភាក្សាការងារជាមួយ ឯកឧត្តម Nuttavudh PHOTISARO ឯកអគ្គរាជទូតព្រះរាជាណាចក្រថៃឡង់ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ដើម្បីទទួលគណៈប្រតិភូសភានៃព្រះរាជាណាចក្រថៃឡង់គ្រោងមកទស្សនកិច្ចនៅព្រះរាជាណាចក្រកម្ពុជា ។/

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៧

ជ.ប្រធានព្រឹទ្ធសភា

អនុប្រធានទី២

**ទេព ងន**

ចម្លងជូនៈ

- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសារ